# ការសំភាសន៍របស់អ្នកមីង ស៊ីម មុំ

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអារ ខៈ អ្នកដែរអោយគេសំភាសន៍មាន ស៊ីម មុំ

## <u>ការសង្ខេបប្រវត្តិរបស់ អ្នកមីង ស៊ីម មុំ</u>

អ្នកមីង ស៊ីម មុំ មានអាយុ58ឆ្នាំ អ្នកមីង ស៊ីម មុំ មានភេទស្រី អ្នកមីង ស៊ីម មុំ មានទីលំនៅបច្ចុប្បន្ននៅភូមិតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណមីងដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់មីង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍មីង ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ ចា៎!!អត់អីទេធ្វើចុះ

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី23ខែ3 ឆ្នាំ2018 ចឹងធ្វើនៅភូមិនឹងភូមិអីគេដែរមីង?

ខៈ ភូមិចាក់អង្រែលើ ភូមិតាគង់

កៈ ភូមិតាគង់ សង្កាត់ចាក់អង្រែលើ?

ខៈ ចា៎!!នឹងហើយ

កៈ នៅខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ?

ខ៖  នៅខ័ណ្ឌមានជ័យទេអូន

ក៖  អ៎ូ!!ខ័ណ្ឌមានជ័យណាមីងណា?

ខ៖  ចា៎!!នឹងហើយ

ក៖  អ៎ូ!!សំទោស ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ
ចឹងសំរាប់មីងឈ្មោះពេញរបស់មីងនឹងមានឈ្មោះ អីគេដែរទៅមីង?

ខ៖  ខ្ញុំឈ្មោះស៊ីម មុំ

ក៖  មានឈ្មោះស៊ីម មុំ ចុះមានឈ្មោះហៅក្រៅដែរទេមីង?

ខ៖  អត់ទេមានតែឈ្មោះមួយនឹងសំរាប់ហៅនឹង

ក៖  ចុះកាលពីក្មេងនឹងមានធ្លាប់មាននរណាហៅឈ្មោះមិត្តភក្តិអីផ្សេងទេ?

ខ៖  អត់ទេហៅតែឈ្មោះមួយនឹង

ក៖  បាទមីង ចុះមីងសព្វថ្ងៃនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖  ខ្ញុំអាយុ58ឆ្នាំហើយនឹង

ក៖  ចុះមីងមានដឹងថាមីងកើតនៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខ៖  ស្រេចតែអូនឯងនេះទេ

ក៖  អ៎ូ!!បាទចឹងមីងកើតនៅឆ្នាំ1960 ចុះថ្ងៃខែមីងមានចងចាំទេ?

ខ៖  ខែផុតទ្រូបុត្រ

ក៖  ខែផុតទ្រូបុត្រ ចុះខែបារាំងនឹងខែអីគេដែរមីង?

ខ៖  ខែភ្លេចបាត់ហើយអូនអើយតាំងពីអាពតនឹងមកហោស

ក៖  អ៎ូ!!បាទ ចុះឆ្នាំខ្មែរមីងមានដឹងថាឆ្នាំជីទេមីង ឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  ខ្ញុំឆ្នាំឆ្លូវនឹង

ក៖  ចឹងមីងឆ្នាំឆ្លូវណាមីង?

ខ៖ ចា៎!!នឹងហើយ

ក៖ អ៊ូ!!បាទចុះមីងកើតនៅណាវិញមីង?

ខ៖ ខ្ញុំកើតនៅកំពង់ចាមនឹង

ក៖ កើតនៅកំពង់ចាមប៉ុន្តែអីឃុំអីមីថមានចងចាំទេ?

ខ៖ ភូមិតាមុល ខេត្តកំពង់ចាមដែរតើនឹង

ក៖ ចុះនៅស្រុកអីគេដែរទៅមីង?

ខ៖ នៅក្នុងស្រុកស្រីសន្ធរ

ក៖ ចឹងនៅក្នុងស្រុកស្រីសន្ធរណាមីង?

ខ៖ នឹងហើយចឹង

ក៖ ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួន7នាក់

ក៖ ចុះមីងជាកូនទីប៉ុន្មានដែរទៅមីង?

ខ៖ ខ្ញុំជាកូនទី4ស្រី មើលកូនស្រីទីមួយទេ បើបងប្រុសនឹងមានបីនាក់ទៀតនឹង

ក៖ ប៉ុន្តែមានស្រីប៉ុន្មានប្រុសប៉ុន្មានដែរមីង?

ខ៖ មានស្រីបួននាក់ប៉ុន្តែស្លាប់បាត់អស់ហើយនឹង រាល់ថ្ងៃនឹងនៅតែពីរនាក់ទេនឹង

ក៖ ចឹងមានស្រី4នាក់ នឹងប្រុស3នាក់?

ខ៖ នឹងហើយ

ក៖ ចុះមីង
ចុះមីងមានចងចាំឈ្មោះបងប្អូនរបស់មីងទេថាពួកគាត់មានឈ្មោះអីគេខ្លះដែរទៅ?

ខ៖ មានឈ្មោះវណ្ណី

ក៖ នឹងបងធំណាមីងណា?

ខ៖  បងធំជាងគេនឹងឈ្មោះវណ្ណី ប៉ុន្តែគាត់នៅជាមួយតានឹងដាក់ឈ្មោះគិតវណ្ណី

ក៖  បាទដល់ពេលដែរបងទី2វិញអុំ?

ខ៖  ណៃឈ្មោះវណ្ណយ

ក៖  ចុះបងទី3វិញមីង?

ខ៖  ឈ្មោះវណ្ណា

ក៖  ចឹងសំរាប់បងទី4នឹងមីង?

ខ៖  ចាំ!!ខ្ញុំនឹងហើយ

ក៖  ចុះប្អូនទី5វិញមីង?

ខ៖  ប្អូនទី5នឹងមានឈ្មោះវ៉ា

ក៖  ឈ្មោះវ៉ា ចុះទី6វិញមីង?

ខ៖  ទី6នឹងមានឈ្មោះរី

ក៖  ចុះកូនពៅគេវិញមីង?

ខ៖  មានឈ្មោះពៅនឹងហាស

ក៖  ប៉ុន្តែដូចជាពួកគាត់នឹងមានស្លាប់ប៉ុន្មាននាក់នឹងនៅប៉ុន្មាននាក់ដែរទៅមីង?

ខ៖  ឥឡូវនឹងនៅប្រុសតែពីរនាក់ទេ មានប្រុសពីរនាក់នឹងស្រីពីរនាក់នឹង

ក៖  អូ៎!!ក្រៅពីរនឹងពួកគាត់ស្លាប់ចុះពួកគាត់ស្លាប់នឹងនៅជំនាន់?

ខ៖  ស្លាប់នឹងនៅជំនាន់ខ្មែរស ជំនាន់លុនណុលនឹងគេយកទៅធ្វើជាទាហ៊ានហាស

ក៖  ប៉ុន្តែពួកគាត់ស្លាប់ដោយសារតែអីគេដែរដោយសារតែអត់បាយ រឺមួយក៏អីគេវិញមីង?

ខ៖  គាត់ស្លាប់ដោយសារតែគេបញ្ជូនធ្វើជាទាហ៊ានមកធ្វើខ្មែរស
ពីដើមនឹងគេចាប់ដាក់ឡាន គេយកទៅធ្វើច្បាំងជាមួយជំនាន់លុនណុលនឹងហាស

ក៖  អូ៎!!បាទមីងបាទ?

ខ៖ គេច្បាំងគ្នានឹង

ក៖ ចុះមីងធ្លាប់ចងចាំអនុស្សាវរីយ៍កាលពីនៅក្មេងៗថាធ្លាប់បានលេងអីគេខ្លះដែរជាមួយពួកគាត់ដែរចឹងទេមីង ដូចជាលេងបិទពួន លេងបាយខំ លេងឡឹកបាយឡអីចឹងហាស?

ខ៖ ធ្លាប់ដែរ

ក៖ ប៉ុន្តែពេលណុងមីងលេងអីគេដែរទៅមីង?

ខ៖ លេងបិទពួនក្រោមទឹកភ្លៀង

ក៖ ចុះមានអីលេងជាមួយគ្នាទៀតទេមីង?

ខ៖ មានលេងរអិលដៃពីទន្លេចុះមកព្រែកនឹង

ក៖ បាទមីងអូ ចុះបងប្អូនរបស់មីងដែរគាត់នៅរស់នឹងឥឡូវនឹងគាត់នៅណាដែរទៅមីង?

ខ៖ គាត់នៅធ្វើការងារនៅភ្នំពេញហោសអូន

ក៖ ចឹងនៅភ្នំពេញនឹងទាំងអស់គ្នាហោសមីង?

ខ៖ ចា៎!!!នឹងហើយ

ក៖ ចុះគាត់ធ្វើការងារអីគេវិញមីង?

ខ៖ ប្អូនប្រុសមួយបានធ្វើសំណង់ហោស

ក៖ ប៉ុន្តែមានប្រុសផ្សេងទៀតធ្វើអីគេ?

ខ៖ មានប្អូនស្រីមួយនឹងធ្វើជាអនាម័យ

ក៖ ប៉ុន្តែពួកគាត់មានគ្រួសារអស់ហើយណាមីង?

ខ៖ ពួកគាត់ច្រើនតែមេម៉ាយនឹង

ក៖ អូ៎!!ចឹងហោសមីង
បាទចុះអត់អីទេមីងឪពុករបស់មីងនឹងគាត់មានឈ្មោះអីគេដែរទៅមីង?

ខ៖ គាត់ឈ្មោះណៃម ស៊ីម

កៈ ចុះដល់ឥឡូវនឹងគាត់អាយុប៉ុន្មានមីងមានដឹងទេ?

ខៈ គាត់ប្រហែលជាខ្ទង់ប៉ែតជាងនឹងប៉ុន្តែគាត់ស្លាប់នៅជំនាន់អាពតហាស

កៈ អូ៎!!បាទមីងចុះឪពុករបស់មីងនឹងគាត់កើតនៅណាដែរមីង?

ខៈ គាត់នៅស្វាស៊ីសុផុត

កៈ អូ៎!!គាត់នៅខេត្តបន្ទាយមានជ័យហោសមីង?

ខៈ ចា៎!!នឹងហើយ

កៈ ចុះម្ដាយរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់មានឈ្មោះគិត រឹម

កៈ គាត់ឈ្មោះគិត រឹម ចុះគាត់ដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរមីង គាត់មានអាយុប្អូនតាប៉ុន្មានឆ្នាំដែរទៅមីង?

ខៈ គាត់ប្រហែលជាអាយុចិតជាងហើយអូន

កៈ គាត់អាយុចិតជាងហោសមីង?

ខៈ នឹងហើយចឹង

កៈ ចុះគាត់រស់នៅណាដែរទៅមីង?

ខៈ គាតរស់នៅស្រុកនឹង

កៈ គាត់រសនៅកំពង់ចាមណោះមីង?

ខៈ ចា៎!!នឹងហើយនៅណុង

កៈ ចុះកាលពីឪពុករបស់មីង ចុះគាត់នៅរស់រឺមួយគាត់ស្លាប់ហើយមីង?

ខៈ គាត់នៅរស់ទេ

កៈ ចឹងគាត់នៅរស់ទាំងអស់គ្នាហោសមីង?

ខៈ អត់ទេស្លាប់តែឪពុកនឹងមួយទេ

កៈ អូ!!ចឹងកាលឪពុកគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ គាត់បើកឡានទៅភ្នំពេញនឹងតើ!!

កៈ គាត់បើកឡានអោយក្រុមហ៊ុនគេហោសមីង?

ខៈ នេះបើកអោយញ្ញើបផុននៅចាក់អង្រែលើនឹងហាស

កៈ អូ!!បាទប៉ុន្តែឪពុករបស់មីងនឹងគាត់កាចរឺមួយក៏គាត់ស្លូតដែរមីង?

ខៈ ប៉ាស្លូតទេ ម៉ាក់កាច

កៈ
អូ!!យាយកាចណាចុះយាយឥឡូវនឹងពីមុនហាសកាលគាត់នៅក្រមុំនឹងគាត់បានតាដំបូងៗ ៗហាស គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ កាលពីដើមនឹងគាត់អ្នកមានគាត់ក្មួយលោកសារ៉ុន នៅខាងកំពង់ចាមនឹង

កៈ អូ!!បាទមីងបាទ?

ខៈ តាយាយរបស់គាត់មាន

កៈ បាទមីងបាទ?

ខៈ គាត់ក៏ធ្វូរធាដែរនៅជំនាន់លុនណុលនឹងហាស

កៈ ប៉ុន្តែឥឡូវនឹងគាត់នៅណាដែរមីង?

ខៈ គាត់នៅស្រុក

កៈ គាត់នៅស្រុក ចឹងយូរមីងទៅលេងគាត់ម្តងរឺមួយយ៉ាងម៉េចដែរមីង?

ខៈ យើងផ្ញើរលុយទៅរាល់ខែ

កៈ អូ!!ចុះគាត់នៅជាមួយនរណាគេដែរនៅស្រុកនឹងមីង?

ខៈ គាត់នៅម្នាក់ឯងកូនៗៗនឹងមករកលុយអស់ហើយនឹង

កៈ អូ!!ប៉ុន្តែគាត់នៅខេត្តកំពង់ចាមនឹង

ខ៖ ចាំ!!នឹងហើយ

ក៖ អូ!!បាទមីង
ចុះមានមានចងចាំអនុស្សាវរីយ៍អីកាលពីមីងនៅជាមួយពួកគាត់នៅក្មេងធ្លាប់បានលេងអីជាមួយគ្នាដែរទេមីង?

ខ៖ ខ្ញុំនៅជាមួយតា តាយាយនៅស្រុកទាំងអស់នឹង

ក៖ ប៉ុន្តែមីងមានចងចាំថាមីងមានធ្លាប់ទៅស្រែអីជាមួយគ្នារឺមួយធ្វើម្ហូបញ៉ាំបាយរឺមួយដាំបាយញ៉ាំអីជាមួយគ្នាដែរទេ?

ខ៖ ធ្លាប់យាយបំរើខ្ញុំ

ក៖ អូ!!ម៉េចចឹងមីង?

ខ៖ ដូចថាធ្លាប់នៅជាមួយគាត់ធ្លាប់ញ៉ាំបាយជាមួយគាត់ចឹងហាស

ក៖ បាទមីងបាទ?

ខ៖ ម៉ាក់កាចណាស់មិនអាចនៅជាមួយគាត់បានទេ

ក៖ អូ!!គាត់កាចខ្លាំងហោសមីង?

ខ៖ គាត់នឹងកាលពីមុននឹងខ្ញុំមិនបានរៀនទេគាត់បានខ្ញុំមកភ្នំពេញអោយមកមើលប្អូន

ក៖ អូ!!ចឹងហោសមីង?

ខ៖ គាត់វៃរហូតនឹងណាស់

ក៖ អូ!!បាទមីងបាទ?

ខ៖ តាគាត់នៅអូរជ្រៅនឹងគាត់មិនដែរបាននៅជាមួយខ្ញុំទេគាត់រកស៊ីនៅណុងហាស

ក៖ បាទមីងបាទ?

ខ៖ គាត់ចេញចូលនៅថៃផងនឹង

ក៖ បាទមីងបាទ ចុះតាគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងដែរទេមីង?

ខ៖ ខ្ញុំមិនដែរស្គាល់ស្រុកគាត់ទេគ្រាន់តែគាត់ថាភូមិស្រុកគាត់នៅនឹង

កៈ
ចង់និយាយថាតាកាលពីគាត់នៅក្មេងនឹងគាត់ធ្លាប់ធ្វើស្រែរឺមួយក៏ធ្វើអីគាត់មានដែរប្រាប់ទេ
?

ខៈ គាត់អត់បងប្អូនគាត់ធ្វើស្រែប៉ុន្តែគាត់មួយគាត់ជាអ្នកបើកឡានកាលពីក្មេងហាស

កៈ អ៎ូ!!បាទមីងបាទ
ចុះយាយាគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងដែរទេ?

ខៈ ម៉ាក់ហោស
ម៉ាក់គាត់អត់ដែរធ្វើអីគេទេគាត់ដេកនៅតែផ្ទះទេគាត់ត្បាញមុងត្បាញ់អីកាលណុងហាស

កៈ ដោយសារតែគ្រួសាររបស់គាត់មានណាមីង?

ខៈ គាត់ធូរធា

កៈ បាទមីង ចុះយាយធ្លាប់ប្រាប់យាយតាខាងម្តាយទៅមីងទេថាមីងមានស្គាល់ដែរទេ
ដូចថាគាត់មានឈ្មោះអីគេដែរចឹងហាស?

ខៈ ណែតារបស់ខ្ញុំនឹងឈ្មោះតាគិត

កៈ ចុះយាយខាងយាយវិញ?

ខៈ យាយឈ្មោះយាយទូច

កៈ ចុះគាត់កើតនៅណាមីងមានដឹងទេ?

ខៈ គាត់កើតនៅកំពង់ចាមទាំងអស់នឹងណាស់

កៈ ចុះយាយតាខាងឪពុកវិញមីង?

ខៈ គាត់នៅកំពង់ចាមដែរនឹង

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរមីងយាយតាខាងឪពុកហាស?

ខៈ អ៎ូ!!ខ្ញុំអត់ដែរបានស្គាល់ទេខាងតារបស់ខ្ញុំហោស

កៈ អ៎ូ!!បាទមីងបាទ?

ខ៖  ខ្ញុំអត់ដែរបានស្គាល់ទេ

ក៖  ចឹងគាត់កើតនៅណាក៏មីងអត់ដឹងដែរណាមីង?

ខ៖  ប៉ាគ្រាន់តែគាត់ប្រាប់ថាគាត់ស្តាយ នៅជំនាន់អាពតនឹងហាស

ក៖  បាទមីងបាទ?

ខ៖  គាត់មុននឹងគាត់ស្លាប់គាត់ស្តាយហាសគាត់មិនបានអោយខ្ញុំស្គាល់ស្រុកហាស

ក៖  អូ្ន!!ពេលណុងមីងនៅតូចៗទេមែនទេមីង?

ខ៖  ជំនាន់អាពតនឹងខ្ញុំកំពង់ចល័តលេខ1ហើយនឹងរែកដីហាស

ក៖  យ៉ាងម៉េចវិញទៅមីង?

ខ៖  រែកដីនៅក្នុងនឹងហាសអាយុ16-
17ឆ្នាំហើយនឹងពោពេញទៅដោយរែកដីនឹងវាស់គីបហាស មួយថ្ងៃនឹងអោយបានបីគីប
បើវាស់មិនបានបីគីបទេគេមិនអោយបាយស៊ីទេ

ក៖  ប៉ុន្តែពេលណុងគេអោយមីងទៅណាដែរទៅមីង?

ខ៖  គេអោយទៅកាលណុងគេជំលាស់ទៅខាងកំពង់ធំនឹងហាស
គេទៅដល់ស្រុកកំពង់ចាមនឹងហើយ
គេអត់អោយនៅកំពង់ចាមទេគេអោយជំលាស់ទៅកំពង់ធំទៀតនឹង

ក៖  អូ្ន!!បាទមីងបាទ?

ខ៖  ពីព្រោះអីអ្នកដែរចេញពីជំនាន់ពីភ្នមពេញនឹងគេមិនអោយនៅទេ

ក៖  បាទមីងចុះ យើងនៅជាក្រុមគ្រួសារវឺមួយក៏យើងនៅម្នាក់ឯងដែរមីង
ពេលដែរគេជំលាស់ទៅណុង?

ខ៖  គេអោយទៅទាំងអស់គ្នាប៉ុន្តែទៅដល់ណុងគេបំបែកហាស

ក៖  បាទមីងបាទ?

ខ៖  យើងទៅចល័តលេខ1ហើយ

កៈ មីងទៅ?

ខៈ ប៉ាម៉ាក់គេអោយទៅនឹងគេបំបែកគ្នាអស់ហើយនឹងប៉ុន្តែពេលណុងមីងនៅកងនារី

កៈ បាទពេលណុងបងប្អូនរបស់មីងនឹងនៅណាខ្លះដែរទៅ?

ខៈ នៅមើលនៅបានបួននាក់

កៈ ប៉ុន្តែគាត់?

ខៈ ប្អូនស្រីៗបីនាក់ទាំងខ្ញុំនឹងហាស នឹងប្អូនប្រុសមួយទៀតបានបួននាក់

កៈ ប៉ុន្តែពួកគាត់មានអ្នកស្លាប់នៅក្នុងជំនាន់ពលពតនឹងអត់មីង?

ខៈ មានតែប៉ាទេដែរស្លាប់នៅជំនាន់អាពតនឹង

កៈ ប៉ុន្តែបើបងប្អូននឹងស្លាប់មុនជំនាន់អាពតនឹង?

ខៈ ប៉ុន្តែបងប្អូនពេលដែរជំនាន់លុនណុលនឹងមានស្លាប់អស់ពីរទៅបីនាក់

កៈ ចឹងដូចជាឪពុករបស់មីងគាត់កើតអីបានជាគាត់ស្លាប់ចឹងហាសមីង?

ខៈ
គាត់ពិបាកចិត្តពេកគាត់មកពីចល័តពេកគាត់ងត់មានបាយញាំហើយគាត់ឃើញកូនគាត់វេទនា ចឹងទៅគាត់ក៏លេបថ្នាំទៅ

កៈ អូ៎!!មិនមែនគាត់ស្លាប់ដោយសារតែអត់បាយផងគាត់លេបថ្នាំហោសមីង?

ខៈ
គាត់អត់មានបាយញាំគាត់អ្នកមូលដ្ឋានគេមានបាយញាំម៉ាក់អត់មានបាយញាំគាត់មិនអោយគេ ញាំហើយគាត់ពិបាកចិត្តណាស់ដែរឃើញកូនៗៗអត់ចឹង

កៈ បាទមីងបាទ?

ខៈ ហើយគាត់ដេញអោយខ្ញុំទៅសុំស្រូវគេនឹង

កៈ អូ៎!!បាទមីងបាទ?

ខ៖ ហើយដល់ពេលចឹងគាត់ក៏បានលេបថ្នាំទៅ ពេលល្ងាចគាត់និយាយថាគាត់ធ្លាប់ចិញ្ចឹមប្រពន្ធ ដល់ប្រពន្ធ

ក៖ ប្រពន្ធគាត់អត់បានធ្វើអីដាក់គាត់វិញចឹងហោសមីង?

ខ៖ នឹងហើយ

ក៖ អូ៎!!បាទមីងបាទ ចុះចឹងមានន័យថាអស់3ឆ្នាំ 8ខែនឹងមីងនៅកំពង់ធំរហូតហោសមីង?

ខ៖ ចាំ!!គេអោយទៅចល័តដល់ស្មោងនៅប្រសាទអង្គរ

ក៖ បាទមីងបាទ?

ខ៖ ទៅចល័តដល់ណុងនឹងពីរនាក់ប៉ាគេអោយទៅចល័ត

ក៖ អូ៎!!បាទមីង?

ខ៖ ហើយអត់មានទេបបរវាវកឃ្លោកនឹង

ក៖ នឹងរបបអាហាររបស់គេហោសមីង?

ខ៖ នឹងហើយគេជោកមួយជោកមកវាវកឃ្លោកនឹងមានកាក់បានតែពីរស្លាបព្រាទេ ហើយគាត់បេះត្រកួន ហាន់ដាក់ថែមហាន់ៗដាក់ទៅស៊ីឡើងហើមដៃឈឺទៅ

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ វេទនាណាស់

ក៖ បាទបងប្អូនរបស់មីងនឹងអត់នៅជិតមីងទេណ?

ខ៖ បែកគ្នាអស់ហើយគេកងចល័តគេកងកុមារគេតូចៗគេបានរបបញ៉ាំបានល្អ អ្នកដែរនៅចល័តខាងណុងក្នុងមួយឆ្នាំនឹងគេអោយញ៉ាំបាយបានពីរថ្ងៃនឹង ចូលឆ្នាំបានបីថ្ងៃ បាយមួយឆ្នាំបានបីដង ក្រៅពីនឹងបបរនៅរាវៗនឹង

ក៖ បាទមីងបាទ?

ខ៖ នឹងហើយវាចឹង

ក៖ ចុះពេលដៃរដាច់ពលពតនឹងមីងបានរៀបអាពាហ៍ពិពាហ៍នៅមីង?

ខ៖  ខ្ញុំទើបតែអាយុ17-18ឆ្នាំនឹងចេញពីអាពតនឹងមក

ក៖  អូ៎!!បាទមីង
ចឹងពេលដែរដាច់ពីពលពតនឹងក្រុមគ្រួសាររបស់មីងនឹងមកជួបជុំគ្នាវិញហើយណាមីង?

ខ៖  ដល់ពេលណុងគេវៃដាច់ទៅពេលណុងតា ពេលណុងអត់ទេខ្ញុំរត់ចេញពីផ្ទះ
រត់ចេញពីភូមិគេហៅ ភូមិស្ទឹងកែង
ភូមិបញ្ញាជីនឹងហាសនៅកំពង់ធំនឹងខ្ញុំបានរត់ចេញមកពីចល័តវិញនឹងខ្ញុំរត់ចេញ
រត់ចេញពីភូមិនឹងប៉ានិយាយថាបើប៉ាស្លាប់ហើយកុំនៅនឹងអី ពីព្រោះតែម៉ាក់ចិត្តមិនសូវបាន
គួរតែចេញពីកន្លែងនឹងទៅណាស់

ក៖  បាទមីងបាទ?

ខ៖  ចេញទៅក៏ខ្ញុំនឹងរត់ទៅណោះរត់ទាល់តែហួសគេហៅឈូករវាងទៅឆ្ងាយណាស់

ក៖  ទៅឈូករវាងនឹងនៅណាវិញមីង?

ខ៖  ទៅហួសគេហៅចោមថៅនៅស្រុកលើហាស
ដល់ពេលដែរទៅៗក៏ចូលព្រៃគប់ធំៗហាស

ក៖  នៅប្រាសាទព្រៃគុកយើហានៅកំពង់ធំនឹងហោសមីង?

ខ៖
អើរនឹងហើយព្រៃគុកព្រៃគុកយើងក៏ដើរចូលព្រៃគុកទៅម៉ាជំនាន់ណុងបើអូនមិនជឿមិនជឿ
ទេណាស់

ក៖  បាទមីងបាទ?

ខ៖  មួយជំនាន់ណុងមានអ្នកតា

ក៖  បាទមីងបាទ?

ខ៖  ខ្ញុំដើរទៅនឹងជើងហើមផងនឹង
ដើរទៅបានបីជំហ៊ានបានដួលនៅលើដីខ្សាច់ត្រឹមៗនឹង ទៅកូនអ្នកតាចេញមកថា
ចៅៗចៅឯងទៅណា

ក៖  អូ៎!!ចឹងហោសមីង?

ខ៖ នឹងហើយខ្ញុំថាលោកតាប៉ារបស់ខ្ញុំថាប៉ាអោយទៅខាងឈូករវាងប៉ុន្តែខ្ញុំអត់ស្គាល់ទេ

ក៖ អ៎ូ!!ខ្ញុំសុំសួរមួយមីងកូនលោកតាចេញមកអោយយើងឃើញតែម្តងហោសមីង?

ខ៖ នឹងហើយកាន់ឈើច្រត់កាលពីដើមនឹងប្រាសាទព្រៃគុកយើងមានហាស

ក៖ ប៉ុន្តែគេអោយយើងឃើញតែម្នាក់ឯងរឺយ៉ាងម៉េចដែរមីង?

ខ៖ គេអោយឃើញតែខ្លួនយើងទេពីព្រោះព្រៃខ្លានឹង

ក៖ បាទមីងប៉ុន្តែយើងដើរទៅម្នាក់ឯងណាមីង?

ខ៖ នឹងហើយដើរចូលព្រៃតែម្តងនឹងហាសពីព្រោះប៉ាគាត់ថាញ្ញាណព្រលឹងគាត់នៅ
តែជាប់ខ្លួនយើងចឹងហាស

ក៖ បាទមីងបាទចឹង?

ខ៖ ពីព្រោះគាត់អាណិតពិបាកជាងគេនឹង

ក៖ បាទមីងបាទ?

ខ៖
គាត់ដើរចូលទៅបានតែបីជំហ៊ានអីនឹងកូនថាប៉ាម៉េចកូនទៅរកឃើញទៅទៅដល់នេះទៅកូ
នឯង
ចេញពីអូរសាលាមកកាលណុងគេអោយដេកពេទ្យហាសចេញពីអូរសាលាមកចេញមក
ព្រៃមកឃើញ ហើយដើរមកបីជំហ៊ានហើយកូនឯងនឹងឃើញកន្លែងនឹងហើយ

ក៖ ចឹងណាមីង?

ខ៖ ពេលដែរដួលនៅក្នុងព្រៃគុកនឹងទៅ
ក៏លោកតាចិនស្លៀកពាក់សកាន់ឈើច្រត់ថាអាថៅទៅណា
ខ្ញុំកាណាអត់ស្គាល់ផ្លូវដល់ពេលណុងផ្លូវបែកជាបី
គាត់សួរថាថៅទៅផ្លូវណាហើយខ្ញុំថាខ្ញុំកាណាអត់
ស្គាល់ទេលោកតាដល់ពេលចឹងលោកតាថាផ្លូវវាមានជាបី មានផ្លូវវៀចផ្លូវកោង
ផ្លូវកណ្តាលផ្លូវល្អថៅទៅ ចុះដើរបានបីជំហ៊ានថៅឯងទៅជួបគេហើយ

ក៖ ប៉ុន្តែពេល?

ខ៖
ប៉ុន្តែនៅពេលណុងលោកតាអោយនេះខ្ញុំមួយហាសប៉ុន្តែខ្ញុំប្រើខ្ញុំកាន់កាប់អត់បានហាសគេ
ហៅ ស្នាំហោះហាសលោកតា

ក៖ ស្នាំងហោះនឹងជាចញ្ចៀនមែនមីង?

ខ៖ ជានេះទេជាភ្លុកដូចភ្លុកចឹង

ក៖ អូ៎!!បាទមីង?

ខ៖
កន្លែងណុងលោកតាថាអោយទៅយកខ្លួនរៀងកាយលើកថ្វាយបង្គំឡើងទៅលើទៅមួយជំ
នាន់ណុង មានអ្នកបង់បទបានកើនណាស់

ក៖ បាទមីងបាទ?

ខ៖
ដល់នេះក៏លើកចឹងទៅក៏លាលោកតាក៏លើកចឹងទៅដើរបានបីជំហ៊ានទេទៅដល់ភូមិគេភ្លា
ម ទៅក៏ដួលតែបីជំហ៊ាន
ឈានបីជំហ៊ានដែរទៅដួលទៅបានអ្នកស្រុកនៅភូមិត្រើងនឹងហាស
មិនមែនត្រើងក្លុងយើងកំពង់ចាមទេណាស់
ត្រើងចោមថៅនៅឈូករវាងនៅឯខាងស្រុកលើហោសនឹងហាស

ក៖ បាទមីង?

ខ៖
ទៅក៏គេរើសជាខ្យល់ហាសពេលនេះជាតិខ្យល់ដួលនឹងដល់ហើយគេរើសដាក់រទេះហាស
អីដើរ លែងរួចហើយនឹង

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ ចា៎!!ចឹងហើយមានការពិតមានមែន

ក៖ បាទមីងបាទ?

ខ៖ អ្នកពូកែមានការពីដើមហាស

កៈ  បាទមានមែនមីង?

ខៈ  មានមែនហាស

កៈ  ចុះប៉ុន្តែឪពុករបស់មីងនឹងគាត់ស្លាប់នៅឆ្នាំ?

ខៈ  នៅរវាងបីខែ

កៈ  ដាច់ពលពត?

ខៈ  ចាំ!!គាត់ដឹងហាសកូននៅតែបីខែទៀតទេដាច់ហើយកូនឯងនៅទ្រាំកុំស្លាប់តាមប៉ាអី

កៈ
ចុះហេតុអីាបានជាគាត់ដឹងថាគាត់នៅបីខែទៀតស្លាប់ដដែរហេតុអីបានជាគាត់សំលាប់ខ្លួនចឹង?

ខៈ  គាត់ឈឺចាប់ណាស់
គាត់ឈឺចាប់នៅជំនាន់ពលពតនឹងគេអោយម៉ាក់អោយរៀបមានប្តីផ្សេងទៀតនឹងហាស

កៈ  អូ៎!!ចឹងហោស?

ខៈ  គាត់ឈឺចាប់ហាសគាត់មិនអាចរស់នៅបានទេ

កៈ  ចឹងណាមីង?

ខៈ  ប៉ុន្តែយប់ណុងគាត់ឃ្លានសាច់ណាស់
គាត់យកដែកកេះកេះនឹងគាត់ចាប់បានកណ្តុរមួយគាត់ដុត
អោយខ្ញុំញាំុនឹងកណ្តុរមួយនឹងគាត់ថាកូនញាំទៅគាត់ថាឃ្លានណាស់

កៈ  អូ៎!!បាទមីងបាទ?

ខៈ  នឹងហើយ

កៈ  ចឹងរហូតទាល់តែដាច់ពលពតនឹងមកបានមីងស្រួលវិញហើយណាមីង?

ខៈ  បីខែបានខ្ញុំរត់ទៅបានរវាងនឹងបាន6-
7ខែញ្ញាណប៉ាមកហៅទៀតថាកូនអើយកូនឯងរស់នៅ
បានហើយកូនរត់មកមើលប្អូនវិញបីខែទៀតនឹងស្រុកគេដាច់ហើយណាស់

កៈ បាទមីងបាទ?

ខៈ មករត់មកវិញ

កៈ អូ៎!!បាទមីងបាទ?

ខៈ គេហៅនឹងកំពុងពេញចល័តហើយនឹងហាស
ទៅចល័តនឹងចំចល័តពួកសង្កាត់ពង់ក្រពើហាស
នៅកំពង់ធំនឹងគេហៅសង្កាត់ពង់ក្រពើហើយ

កៈ បាទមីងបាទ?

ខៈ
ខ្ញុំសាលាទអូរសាលាទៅក៏ហើយមកវិញទៅក៏សុំគេមកបាននេះបានមកដល់ស្រុកវិញនឹង

កៈ ចឹងហោសមីង?

ខៈ
មកដល់ស្រុកវិញមកដល់កន្លែងប្អូនៗនៅនឹងហាសម៉ែថាអញ់ស្មានតែហ្វែងស្លាប់បាត់ហើយ នឹងហាសខ្លាស៊ីស្លាប់បាត់ហើយខ្ញុំថា
ខ្ញុំថាម៉ែខ្ញុំអត់ស្លាប់ទេខ្ញុំរស់ដើម្បីជួយប្អូនដល់នេះទៅ បីខែនឹងគឺវែដាច់ទៅ

កៈ ចឹងបាទមីង?

ខៈ វែដាច់ទៅគាត់ឈប់អោយដើរជាមួយទៀតគាត់ថាហែងទៅណាក៏ទៅទៅ

កៈ គាត់ឈប់និយាយរកយើងហោស?

ខៈ គាត់អត់អោយយើងដើរជាមួយទេ

កៈ ប៉ុន្តែប្អូនៗផ្សេងនឹងអោយនៅជាមួយ?

ខៈ នឹងហើយខ្ញុំដើរដល់ត្រើងកំពង់ចាមនឹងខ្ញុំត្រូវបែកគ្នាត្រឹមនឹង
ខ្ញុំបានដក់ជំឡុងអោយប្អូនស៊ី ដល់ត្រើងបុសខ្នុរយើងនឹងហាស

កៈ បាទមីងបាទ?

ខ៖ ដល់ពេលណុងគាត់បាននាំប្អូនៗដើរបាត់
គាត់ប្រាប់ថាហែងទៅរកដំឡូងនឹងផ្លែឈើអោយប្អូនៗ
ស៊ីផងទៅដល់ពេលដែរខ្ញុំទៅៗក៏គាត់ទៅចោលបាត់ទៅនឹង

ក៖ អ៎ូ!!ចឹង?

ខ៖ ដល់ដើរពេលដែរចេញមកវិញយំហើយ
ដើរៗហើយទៅដល់កំពង់ចាមព្រៃកសណ្ដែកអីណាហោស

ក៖ បាទមីងបាទ?

ខ៖
ចុះយើងវង្វេងផ្លូវនឹងហើយដល់ពេលដែរទៅនៅផ្ទះជាមួយគេនឹងខ្ញុំប៉ុនអូនឯងនឹងនៅជាមួយនឹង
ដល់ហើយក៏គេជូនមកស្រុកវិញចេះតែយំទៅណាស់ថាហែងស្រុកនៅណាអីនៅណាចឹងទៅ

ក៖ បាទមីងបាទ?

ខ៖ ដល់គេបញ្ជូនមកស្រុកវិញចឹងទៅបានឃើញតែតានឹងយាយស្លាប់បាត់ហើយនឹង

ក៖ អ៎ូ!!បាទមីងបាទត្រូវហើយមីងបាទ ?

ខ៖ នឹងហើយចឹង

ក៖ ចឹងសំរាប់មីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅមីង
ដូចជាជំនះពុះពារឧបសគ្គហាសមីង?

ខ៖ ពិបាកណាស់ពិបាកមកទាល់តែឥឡូវនឹងទៀតនឹង

ក៖ បាទនិយាយរួមពិបាករហូតតែម្ដងណោះមីង?

ខ៖ ខ្លះគេថាពិបាកពីក្មេងពេលដែលចាស់ទៅស្រួលចំណែកអ៊ីពិបាករហូតនឹង

ក៖
អ៎ូ!!បាទមីងគិងថាសំរាប់ពេលណាដែរមីងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតជាងគេនៅក្នុង ឆាកជីវិតរបស់មីងដែរទៅ?

ខ៖
ប្រហែលមីងថាមីងដឹងខ្លួនឯងធ្លាប់ប្រាប់ថាគាត់ធ្លាប់បានចូលរាំងហាសកាលពីជំនាន់លុនណុល
នឹងហាសគាត់ថាគាត់ធ្លាប់រកគ្រូក្នុងរាំងថាមួយជាតិនេះកូនលំបាករាល់ថ្ងៃលុះអវស្សាននឹង

ក៖ ចឹងហោសមីង?

ខ៖ គាត់ផ្ដាំខ្ញុំថាអើយ

ក៖ ចឹងហោសមីង?

ខ៖ គាត់ថាថ្ងៃដែររកចិញ្ចឹមខ្លួនឯងនឹងសំរាកបានតែមួយថ្ងៃទេត្រូវថ្ងៃស្លាប់បាត់ហើយនឹង

ក៖ អូ៎!!បាទមីងបាទនឹង?

ខ៖ គាត់ប្រាប់បានហើយលោកតាប្រាប់ទៀតនឹងខ្ញុំជឿមែន
គាត់ថាចៅឯងវេទនាណាស់មួយជីវិតនេះ
គាត់ថាចៅឯងនឹងមិនមែនមនុស្សធម្មតាទេថាចៅឯងនឹងមានកម្ម

ក៖ ចឹងហោសមីង?

ខ៖ គាត់ថាទ្រាំទៅ
ប៉ុន្តែគាត់ប្រាប់ថាមុននឹងស្លាប់នឹងមិនដែរអោយកូនចៅណាលំបាកទេសំរាកបានតែមួយថ្ងៃទេងូតទឹកសំអាតខ្លួននឹងសំរាមហើយនឹងទៅតែម្ដងនឹង

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ អត់មានពិបាកទេ ខ្ញុំដឹងថ្ងៃខែឆ្នាំខ្ញុំស្លាប់ដែរតើកូន

ក៖ អូ៎!!បាទមីងចឹងបានមីង?

ខ៖ ពីព្រោះខ្ញុំមានតួរបរមី

ក៖ បាទមីងបាទចឹងបានមីងខំប្រឹងធ្វើការណាមីងណា?

ខ៖ នឹងហើយ

ក៖ ចឹងសំរាប់មីងមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅមីង?

ខ៖ មកមានគ្រួសារយូរដែរហើយនឹង

ក៖ ចុះមីងមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេមីង?

ខ៖ អត់មានទេ

ក៖ ចឹងអត់មានទេណាមីង?

ខ៖ នឹងហើយអត់មានទេ

ក៖ ចុះស្វាមីរបស់មីងនឹងមានឈ្មោះអីគេដែរទៅមីង?

ខ៖ មានឈ្មោះឡាក់

ក៖ ចុះគាត់មានឈ្មោះស្អីគេឡាក់ទៅមីង?

ខ៖ មានឈ្មោះអឹង ឡាក់

ក៖ ឈ្មោះអឹងឡាក់
ចុះមីងមានចងចាំថាមីងបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខ៖ ខ្ញុំមានគ្រួសារទីមួយនឹងខ្ញុំរៀបបានជំនាន់គេចងស្រូវហាសគេចងដៃស្រូវហាស

ក៖ បាទមីងបាទ?

ខ៖ ប៉ុន្តែខ្ញុំមិនបានជុំគ្នាទេនឹងខ្ញុំអត់ស្រលាញ់ទេប៉ុន្តែម្តាយចិញ្ចឹមបង្ខំហាស

ក៖ បាទ!!ចឹងមីង?

ខ៖ បានខ្ញុំរត់ចេញពីម្តាយរបស់ខ្ញុំមួយសារទៀតនឹងខ្ញុំបានរត់ទៅចំការលើហាស

ក៖ បាទមីងបាទ?

ខ៖
ហើយខ្ញុំក៏បានរៀបចំហើយក៏ខ្ញុំនឹងខ្ញុំបែកគ្នាទៀតហើយនឹងមកនេះនឹងមានប្តីក្រោយនឹង

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ ប៉ុន្តែខ្ញុំមិនបានដេកពាក់ពន្ធដេកនៅអីទេណាស់

កៈ បាទមីងបាទ?

ខៈ អើរនឹងហើយ

កៈ ចុះនៅពេលស្វាមីរបស់មីងនឹងចូលស្ដីដណ្ដឹងមីងនឹង មានជាថ្លៃទឹកដោះជូនមីងទេ?

ខៈ ខ្ញុំអត់ទេមកយកគ្រួសារក្រោយនឹងអត់មានទេថាយកដោយជួយគ្នានឹងហាស

កៈ បាទមីងបាទ?

ខៈ វាចឹងនឹង

កៈ ចុះមីងមានចេះភាសាខ្មែរទេមីង?

ខៈ អក្សរនឹងហោស?

កៈ មីងធ្លាប់បានរៀនទេមីង?

ខៈ ខ្ញុំរៀនអត់ចេះទេម៉ាក់ប្រញាប់ទៅយកមកមើលប្អូននឹងហាស

កៈ បាទមីងបាទ?

ខៈ នឹងហើយចឹង

កៈ ចុះភាសាអីក្រៅពីភាសាខ្មែរមីងចេះទេ?

ខៈ អត់ទេ

កៈ ចឹងមីងអត់ដែរបានរៀនទេណាមីង?

ខៈ អត់ដែរបានរៀនទេនឹងហាស

កៈ ចុះមីងធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេមីង?

ខៈ
បើមកមើលប្អូននឹងអត់ដែរបានមានពួកម៉ាក់អីទេមានដែរពួកម៉ាក់នៅចាក់អង្រែលើហាស

កៈ បាទមីងបាទ?

ខៈ មានមួយប៉ុន្តែដូចថាពួកគេទៅរកស៊ីរាល់ថ្ងៃដូចថាយើងក៏ដែរបានទៅអើតគេ គេក៏រវល់

កៈ បាទចឹងមីង?

ខៈ ហើយមានតែពួកម៉ាក់ដែរនៅកន្លែងធ្វើការនៅកន្លែងធ្វើការងារនឹងហាសបងប្អូនចឹងទៅមាន

កៈ ប៉ុន្តែមីងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ ធ្លាប់បានធ្វើអីគេខ្លះដែរជាមួយពួកគាត់ចឹងហាសមីង?

ខៈ ធ្វើការងារញ៉ាំបាយជាមួយពួកគាត់ ហាកាបានជួយអោយខ្ញុំរស់ដល់សព្វថ្ងៃនឹងហាស

កៈ អូ៎!!បាទមីងបាទ?

ខៈ ក្រុមហ៊ុននៅហាកានឹងអង្គការ ពីមុនដំបូងនឹងជាអង្គការទេ

កៈ បាទមីងបាទ?

ខៈ ខ្ញុំចេញពីគ្រួសារនឹងទៅខ្ញុំបានបែកបាក់គ្នាហើយទៅខ្ញុំទៅនៅហាកានឹងអាចជួយខ្ញុំអោយបានរស់

កៈ ចឹងហោសមីង?

ខៈ ហើយកូនរបស់ខ្ញុំនឹងនៅបីដៃមួយហាស

កៈ បាទមីងបាទនឹង?

ខៈ រាល់ថ្ងៃនឹងនៅរៀនហើយអាយុ17-18ឆ្នាំនឹង

កៈ គាត់ល្អហើយមីង ចឹងសំរាប់មីងគិតថាជីវិតរបស់មីងនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរទៅមីង?

ខៈ មានការផ្លាស់ប្តូរយ៉ាងម៉េចទៅអូន?

កៈ ផ្លាស់ប្តូរទាំងសុខភាព នឹងទាំងជីវភាពអីចឹងហាសមីង?

ខៈ រាល់ថ្ងៃនឹងខ្ញុំបានតែមួយរស់ចិញ្ចឹមម្តាយនឹង

កៈ អូ៎!!បាទមីងបាទ?

ខៈ ម្ដាយអោយគាត់ជាង10ម៉ឺនចឹងទៅអោយគាត់រស់ទៅណាស់

កៈ បាទមីងបាទ?

ខៈ ទោះគាត់មិនស្រលាញ់យើងក៏យើងត្រូវចិញ្ចឹមពួកគាត់ដែរ

កៈ បាទដោយសារតែគាត់ជាអ្នកផ្ដល់កំណើតអោយយើង?

ខៈ នឹងហើយ

កៈ បាទមីងបាទ?

ខៈ
មិនអាចនេះគាត់ទេហើយរាល់ថ្ងៃនៅកូនមួយបានកូនប្រសារជួយចិញ្ចឹមពេលដែរមកពីរៀន
ហាស

កៈ បាទមីងបាទ?

ខៈ វាចឹងឯង

កៈ ចុះមីងគិតថាមីងចេះច្រៀងអត់ពីមុនហាសមីង?

ខៈ ខ្ញុំអត់ចេះផងនឹង

កៈ ចុះម្ហូបអីដែរមីងចូលចិត្តពិសារជាងគេដែរមីង?

ខៈ ចា៎!!ម្ហូបខ្ញុំចូលចិត្តតែឆា

កៈ អូ៎!!មីងចូលចិត្តឆាហោស?

ខៈ នឹងហើយ

កៈ ចុះមីងគិតថាមីងធ្លាប់ទៅធ្វើការងារនៅវាលស្រែទេមីង?

ខៈ ខ្ញុំអត់ដែរទេជំនាន់អាពតនឹងបានទៅស្ទូងនឹងធ្វើអីចឹងទៅណាស់

កៈ អូ៎!!ទៅស្ទូងនឹងទៅដកណាមីង?

ខ៖ នឹងហើយកាប់ដីរែកដីនៅខាងកំពង់ជំនៅខាងអាទំនប់7មករានឹងហាស

ក៖ បាទមីងបាទខ្ញុំស្គាល់មីង

ខ៖ ចាំៗៗ!!!នឹង

ក៖ ចុះមីងគិតថាមីងមានធ្លាប់ចិញ្ចឹមសត្វទា មាន់ ជ្រូក គោ ក្របីអីទេមីង?

ខ៖ ខ្ញុំនិយាយៗទៅខ្ញុំចិញ្ចឹមសត្វអត់សូវបានទេ
សូម្បីតែរកលាសនឹងក៏ម៉ាក់បង្អត់បាយខ្ញុំដោយសារតែ រកលាសអត់បាននឹងហើយ

ក៖ បាទមីងបាទនឹង?

ខ៖
ដល់ពេលដែររកលាសអត់បានចឹងទៅអត់បានលាសជូរនៅគ្រោយនឹងគេចឹងទៅយើងអត់បានបាយមកញ៉ាំទេ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ដល់ហើយគាត់មិនអោយបាយញ៉ាំចឹងទៅខ្ញុំក៏បានរត់ចេញពីផ្ទះចឹងទៅចឹង

ក៖ ចឹងហោសមីង?

ខ៖ ដោយសារតែអីដោយសារតែខ្ញុំរកអត់បានចឹងទៅ
ពេលណាមុជទឹកនៅក្នុងទន្លេទៅខ្ញុំឃើញតែក្រពើ នឹងចឹងទៅណាស់

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ ចាំ!!ចឹងពីព្រោះខ្ញុំមិនមែនជួវមនុស្សលោកសុទ្ធហាស

ក៖ បាទចឹងហោសមីង?

ខ៖
ពីព្រោះអីយើងមានបរមីកាន់កាប់ម្ល៉ោះហើយយើងចុះទៅនឹងបើព្រះនាងបើមិនទត់ឡើងទេគឺ ខ្ញុំនឹងអោយឃើញក្រពើហើយនឹង ពេលណាដែរយកដៃចាប់ខ្សល់ខ្មៅចឹងទៅចឹង

ក៖ យ៉ាងម៉េចទៅមីង?

ខ៖
បានឃើញអ្នកគេកាន់ព្រះធិមនឹងគេស្រែមកថាមិនអាចមានកម្មមកយកសត្វធាតុមកលក់ចឹងទេ

ក៖ អូ៎!!បាទមីងបាទ?

ខ៖
នឹងហើយម្ល៉ោះហើយនឹងខ្ញុំរកអត់បានម៉ាក់អត់អោយបាយញ៉ាំទេចុះមួយជំនាន់ចេញពីអាពត នឹងមកបាយលាយជាមួយពោតហោស

ក៖ បាទមីងបាទចឹង?

ខ៖ នឹងហើយមិនមែនគាត់ចង់បង្អត់យើងទេប៉ុន្តែមកពីយើងរកវាមិនបាន

ក៖ បាទត្រូវហើយមីង?

ខ៖ ដល់ពេលម្ល៉ោះហើយខ្ញុំបានភាសខ្លួនទៅនៅចំការលើនៅនឹងមានស្រូវតែបីគីឡូទេ ពេលណុងម៉ាក់តាមទាន់ម៉ាក់យកវិញ

ក៖ អូ៎!!ចឹងហោស?

ខ៖ អោយខ្ញុំលើកដៃសំពះគេតាមផ្លូវចឹងតែម្តងនឹង

ក៖ ចឹងគាត់មិនអោយយើងទេចឹង?

ខ៖ គាត់អត់ស្រលាញ់ខ្ញុំទេ

ក៖ ចឹងហោសមីង?

ខ៖ គាត់អត់គិតពីខ្ញុំទេ សូម្បីតែខ្ញុំទៅស៊ីឈ្នួលគេនៅបាត់ដំបងហោស

ក៖ បាទមីងបាទ?

ខ៖ ទៅលក់គុយទាវអោយគេនៅអាយុប្រហែលជា 20ឆ្នាំជាងហើយនឹង

ក៖ បាទមីងបាទ?

ខ៖
ខ្ញុំនឹកស្រុកនឹងផ្ទះណាស់ប៉ុន្តែអ្វីដែរអោយយើងហែលឆ្លងកាត់នឹងប្រុងទៅស្រុកប៉ាហើយនឹងហាស

ក៖ ទៅខាងណា?

ខ៖ ទៅខាងមង្គលបុរីនឹងប៉ុន្តែអត់ស្គាល់នឹងហាស

ក៖ ទៅខាងមង្គលបុរីនឹងហោសមីង?

ខ៖
នឹងហើយកាន់រូបថតប៉ាទៅគេស្គាល់គ្រប់គ្នាប៉ុន្តែខ្ញុំមិនអាចតទៅមុខទៀតខ្ញុំអាណិតប្អូននឹង

ក៖ បាទមីងបាទ?

ខ៖ នឹងហើយយើងអាល័យប្អូននឹងអាល័យម៉ែហាសណាស់

ក៖
បាទមីងចុះមីងគិតថាមីងមានបងប្អូនរឺក៏មាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់មីងនឹងចេះលេងឧបករណ៍ភ្លេងដែរទេ?

ខ៖ អត់មានទេ

ក៖ អត់មានទេហោសមីង?

ខ៖ ចា៎!!អត់

ក៖
ចុះផ្ទះរបស់មីងនឹងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខ៖ នៅជាមួយយាយនឹងគេហៅម៉ូតកាតាំងហាស

ក៖ បាទមីងបាទ?

ខ៖ កាលពីដើមនឹងនៅស្រុកទន្លេដែរគេហៅផ្ទះកាតាំងនឹង

ក៖ បាទមីងបាទ?

ខ៖ នៅជាមួយយាយនឹងហាស

ក៖ ដូចជាផ្ទះឈើណាមីង?

ខ៖ ផ្ទះឈើ

ក៖ អូ៎ៗ!!បាទ ចុះមីងគិតថាមានជំនាញអីដែរមិងគិតថាមីងចេះស្ទាត់ជំនាញទេមីង?

ខ៖ អូ៎!!ខ្លាំងជាងគេនឹងបង្អែមនឹងតែម្តងនឹងហើយ

ក៖ លក់បង្អែមណាមីង?

ខ៖ ធ្វើបង្អែមនឹងហើយ

ក៖ ចឹងធ្វើបង្អែមលក់ណាមីង?

ខ៖ ពីព្រោះគេមិនអោយកាន់សាច់

ក៖ អូ៎!!បាទមីងបាទ?

ខ៖ គាត់ចែកមុខជំនាញមកនឹង

ក៖ បាទមីងបាទ?

ខ៖ អត់ចេះអក្សរមែនប៉ុន្តែគាត់ចែកមុខជំនាញខ្លាំងជាងគេនឹងគឺបង្អែមនឹងតែម្តងនឹងស្អីក៏យើងអាចទៅរួមដែរអោយតែក្រុមហ៊ុនគេសួរថាបងចេះធ្វើអីគេខ្លះហើយគេកំម៉ុងមកយើងអ្នកធ្វើ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ នឹងហើយដល់ពេលដែរគេបញ្ជាមកខួរក្បាលយើងចេញមកហើយនឹង

ក៖ មីងចេះធ្វើមួយនឹងទៅ?

ខ៖ នឹងហើយ

ក៖ ចុះកាលពីក្មេងនឹងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរមីងធំឡើងនឹងមីងចង់ធ្វើអីទេ?

ខ៖ ចង់ធ្វើតែការងារនឹង ហើយមិនសូវចង់លក់ដូរទេ លក់ដូរនឹងពីព្រោះអីនឹងមនុស្សចិត្តលក់ដូរអត់បានហូបទេនឹង ហើយមិនហ៊ានស៊ីភ្នែកជញ្ជីងគេនឹង

កៈ បាទមីងបាទ?

ខៈ
ហើយក៏លក់ៗចឹងក៏អ៊ីទិញខោអាវគេមកលក់ដល់ពេលដែរលក់ទៅនឹងឃើញអ្នកអត់ៗ
នឹង

កៈ ក៏អោយគេទៅនឹង?

ខៈ នឹងអ៊ីក៏អោយគេទៅម្ល៉ោះហើយអ៊ីមិនអាច មិនថាចត្តអាក្រក់ទេមិនលក់បានទេប៉ុន្តែ
អ៊ីមិនអាចលក់ដូរបាន

កៈ បាទត្រូវហើយមីង?

ខៈ មីងបានត្រឹមតែធ្វើការងារអោយគេនឹង

កៈ បានត្រូវហើយមីង
ចុះបើសិនជាចង់អោយមីងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើមីងចង់ផ្តែផ្តាំ
អីទៅពួកគាត់ដែរមីង?

ខៈ អោយពួកគាត់ខំប្រឹងរៀនដើម្បីយកតំរិះពីព្រោះម៉ែឪមិនអាច

កៈ ចិញ្ចឹមពួកគាត់អស់មួយជីវិតដែរទេ?

ខៈ
នឹងហើយចឹងមិនអាចចិញ្ចឹមគាត់អស់មួយជីវិតដែរហើយមានអីធំជាងការរៀនសូត្រទេនឹង
មុខជំនាញ អីទេមានអីយើងអាចរៀនបានទៀតហាសអូន

កៈ បាទមីងត្រូវហើយ

ខៈ
បើថាខំខាន់ជាងគេនឹងម៉ែឪចែកមុខជំនាញអីដែរយើងមិនព្រមហើយនឹងស្តាយក្រោយហើ
យនឹង

កៈ បាទមីងបាទត្រូវហើយនឹង
ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើមីងចង់អោយពួកគាត់
ជៀសវៀងអីគេដែរមីង?

ខ៖  ថ្នាំញៀននឹងផឹកស៊ីលិចកើតនឹងអត់ល្អទេ

ក៖  នឹងដែរមីងចង់អោយពួកគាត់ជៀសវៀងនឹង?

ខ៖
អោយជៀសវៀងនឹងហើយបើកូនចៅទាំងអស់នឹងបើជៀសវៀងដូចថាគេញាំុដែរប៉ុន្តែមានការ មានទានរឺមួយមានបុណ្យទានគេញាំុហាស
បើថាញាំុសាំម៉ូរៃជារៀងរាល់ថ្ងៃអីនឹងអីអត់ចូលចិត្តទេ

ក៖  បាទមីងបាទ?

ខ៖  សូម្បីតែកូនអីនឹងក៏អីលែងនិយាយដែរនឹង

ក៖  បាទមីងបាទចឹង?

ខ៖  ចេះពីអានឹងហើយជាពិសេសជាងគេនឹងគឺថ្នាំញៀននឹងតែម្តងនឹង

ក៖  នេះយើងខ្លាចបំផុតហើយណាមីង?

ខ៖  ចា៎!!នឹងហើយ

ក៖  បាទចឹងមីង?

ខ៖  ហើយយើងខ្លាចណាស់ទីបំផុតនឹងខ្លួចកាបូបយើងនឹងសាក់កាដូយើងហាស
យើងខ្លាចនរណាគេ ស្អប់ចឹងហាសអូនយើងត្រូវតែឆែកមើល

ក៖  ខ្លួចគេយកថ្នាំញៀនអីមកដាក់ក្នុងកាបូបនឹងហោស?

ខ៖  ខ្ញុំខ្លាចហាសណាស់អានឹងគេចាប់ហើយណាស់

ក៖  បាទមីងបាទ?

ខ៖  ចា៎!!នឹងហើយ

ក៖
បាទចឹងជាចុងក្រោយខ្ញុំអរគុណាច្រើនមីងដែរបានអោយខ្ញុំបានអោយខ្ញុំបានពិភាក្សាជាមួយមីងដែរ

ទាក់ទងពីប្រវត្តិរបស់មីងហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាណាស់មីង?

ខ៖ ចា៎!!នឹងហើយ

ក៖ បាទអរគុណច្រើនមីង៕៕៕